ចំ.ក. ដំនើរការបោះឆ្នោតរួមមាន :

-ការចុះឈ្មោះក្នុងបញ្ជីគណបក្សដើម្បីឈរឈ្មោះជាបេក្ខជន

-ការចុះឈ្មោះធ្វើប័ណ្ណដើម្បីបោះឆ្នោត

-ការប្រកាសលទ្ធិ

-យុទ្ធនាការឃោសនាផ្សព្វផ្សាយរកសំលេង

-សកម្មភាពបោះឆ្នោត

-ការរាប់សន្លឹកឆ្នោត

ខ. ស្ថាប័នព្រះមហាក្សត្រ

-ស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា

-រាជរដ្ឋាភិបាល

-ស្ថាប័នតុលាការ

ស្ថាប័ននីមួយៗកើតឡើងដោយការចាត់តាំងខាងក្រោម :

-ស្ថាប័នព្រះមហាក្សត្រ ត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ

-ស្ថាប័នរដ្ឋសភា ត្រូវបានជ្រើសតាំងដោយប្រជាជន(ការបោះឆ្នោត)

-ស្ថាប័នព្រឹទ្ធសភា ត្រូវបានជ្រើសតាំងដោយគណៈបក្សដែលបោះឆ្នោតដោយសកល

-ស្ថប័នរាជរដ្ឋាភិបាល ត្រូវបានជ្រើសតាំងដោយរដ្ឋ

-ស្ថាប័នតុលាការត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សាអង្គចៅក្រម

២៧៦. ចូរធ្វើការប្រៀបធៀបអំពីភាគច្បាស់ចុះរបស់រដ្ឋសភា និងព្រឹទ្ធសភា? រវាង រដ្ឋសភា និងព្រឹទ្ធសភា មួយណាមានអំនាចជាង? ព្រោះអ្វី?

ចំ.ភារកិច្ចរបស់រដ្ឋសភា និងព្រឹទ្ធសភា មានចំនុចខ្លាដូចខាងក្រោម:

+រដ្ឋសភា

-អនុម័តផែនការចរិការរដ្ឋ

-ទទួលពាក្យបណ្តឹង

-បោះឆ្នោតផ្តល់សេចក្តីទុកចិត្ត រឺមិនទុកចិត្តពីរដ្ឋាភិបាល

-ពិនិត្យច្បាប់ដែលរដ្ឋសភាបានអនុម័ត

-ជាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាក្នុងករណី សមស្រប

-បញ្ជូនត្រលប់ទៅរដ្ឋសភា ឱ្យសំរួលឡើងវិញក្នុងករណីមាន ការជំទាស់

រដ្ឋសភា: ជាអ្នកតំនាងរាស្ត្រជាប់ឆ្នោត ដោយវិធីបោះឆ្នោតជាសកលនិងចំពោះ

(តាមប្រព័ន្ធសមាមាត្រ) រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាមានអាយុកំនើត នៅថ្ងៃទី ២៥ កញ្ញា ឆ្នាំ១៩៩៣។

•ព្រឹទ្ធសភា : ជាសភាជាន់ខ្ពស់កើតឡើង ដោយវិធីបោះឆ្នោតជាអសកល មិនចំពោះ។

ព្រឹទ្ធសភាតំនាងសម្ព័ន្ធភាពដែនដីព្រឹទ្ធសភាបង្កើត ឡើងនៅថ្ងៃទី ១៥ មិនា

ឆ្នាំ១៩៩៩ ។រវាងរដ្ឋសភានិងព្រឹទ្ធសភា មានអំនាចជាព្រឹទ្ធសភាត្រង់ អនុម័តលើចរិការ

និងផែនការរដ្ឋនិងសិទ្ធិអំនាចទទួលាក់រាជរដ្ឋាភិបាល ។ចំនែកព្រឹទ្ធសភាមិនអាចទំលាក់រាជរដ្ឋាភិបាលបានឡើយ ។

២៧៧.ក្នុងសិទ្ធិប្រជាធិបតេយ្យមានសិទ្ធិបែងចែក ប៊ីជាច់ពីគ្នា។

ក.តើអំនាចអ្វីខ្លះ? អំនាចណីមួយៗជំនាចឱ្យស្ថាប័ន ឬអង្គការអ្វី?

ខ.តើអំនាចនីមួយៗកកើតឡើងតាមទីធីណាខ្លះ?

ចំ.ក្នុងលទ្ធិប្រជាធិតេយ្យមានការបែងចែក អំនាចប៊ីជាច់ពីគ្នា អំនាចទាំងបីនោះមានគឺ :

ក.អំនាចទាំងបីមានគឺ

-អំនាចនិតិបញ្ញត្តិ មានស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា

-អំនាចនិតិប្រតិបត្តិ មានស្ថាប័នរាជរដ្ឋាភិបាល

-អំនាចតុលាការ មានស្ថាប័នសាលាកជំរះក្តី អង្គចៅក្រម

ខ.ការកកើតឡើងនៅអំនាចនីមួយៗ

•រដ្ឋសភា :រៀបចំបង្កើត ដោយការបោះឆ្នោតជាសកលរបស់ប្រជាជនតាម ប្រព័ន្ធនិងបញ្ជីគណៈបក្ស
ដែលមានសមាជិកយ៉ាងតិច១២០នាក់ (អាណត្តិទី១) បច្ចុប្បន្នមានសមាជិក ១២រូប តំនាងរាស្ត្រ ឬតំនាងសភា
ដែលជ្រើសរើសបេក្ខជន ដែលមានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ជាតខ្មែរពីកំនើត
ស្នាក់នៅយ៉ាងតិច១ឆ្នាំក្នុងប្រទេសកម្ពុជា ពីសេសមានឈ្មោះក្នុងបញ្ជីគណៈបក្ស ។រដ្ឋសភាមានធីតិកាល៥ឆ្នាំ
និងផុតកំណត់នៅពេលរដ្ឋសភា ថ្មីចូលកាន់តំណែង ។

•ព្រឹទ្ធសភា :មានសមាជិកស្មើនិងពាក់កណ្តាល ដែលសមាជិករដ្ឋសភា បច្ចុប្បន្ន៦១នាក់
ក្នុងចំនោមសមាជិកព្រឹទ្ធសភា ទាំងអស់មានសមាជិក២រូបដែលតែងតាំងដោយ ព្រះមហាក្សត្រ
និងពីរូបទៀតជ្រើសតាំងដោយ រដ្ឋសភា និងសមាជិកដ៏ទៃជ្រើសតាំងដោយ ការបោះឆ្នោតអសកល។
សមាជិកព្រឹទ្ធសភា មានអាយុយ៉ាងតិច៤០ឆ្នាំ មានសញ្ជាតិខ្មែរពីកំណើត ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ ។

•រាជរដ្ឋាភិបាល: តាមសំណើរពីរដ្ឋសភា
ព្រះមហាក្សត្រក្រទ្រង់ចាត់តាំងវីរៈជនមួយរូបក្នុងចំនោមតំនាងរាស្ត្រនៃគណៈបក្ស ដែលឈ្នះឆ្នោតឱ្យ
ធ្វើជានាយករដ្ឋមន្ត្រី ដើម្បីបង្កើតស្ថាប័ន រាជរដ្ឋាភិបាលវីរៈជនរូបនេះជ្រើសតាំងឬសមាជិកគណៈបក្ស
ដែលមានសំលេងនៅក្នុងសភា ឱ្យកាន់តំនែងផ្សេងក្នុងតំនែងរាជរដ្ឋាភិបាលហើយសុំសេចក្តីទុកចិត្តពីរដ្ឋសភា
។រដ្ឋសភា បានបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ហើយជាក់ថ្វាយព្រះមហាក្សត្រ ទ្រង់ចេញព្រះរាជក្រឹត្យ
តែងតាំងក្នុងសមាជិករាជរដ្ឋាភិបាល។
គណៈរដ្ឋមន្ត្រីធ្វើសច្ចាប្រណិធានរហើយចូលកាន់តំនែង ។

•តុលាការ: សាលាជំរះក្តីគឺតុណភាពបង្កើតតាមសំណើរ របស់ឧត្តមក្រុមប្រឹក្សា
អង្គចៅក្រមដែលមានព្រះមហាក្សត្រជាប្រធាន ទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងចៅក្រម
ព្រះរាជអជ្ញាសាលាជំរះក្តី ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទទួលបន្ទុកព្រាងព្រះរាជក្រឹត្យនោះ ។
**២៧៨.ក្រោយពីបានសិក្សារមេរៀន សិទ្ធិបោះឆ្នោតនៅកម្ពុជា និងឆ្លងតាមរយៈការធ្លាប់ដឹង
បានលឺនូវស្ថានភាពបោះឆ្នោតនៅអាណត្តិទីមួយនិងទីពីរនៅកម្ពុជា ។**

ចំ.នៅកម្ពុជាក្នុងរបបព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ១៩៩៣មកមានការបោះឆ្នោតតាមរបបសភាពនិយម បានពីរលើកមកហើយ ពីអាណត្តិទីមួយនិងទីពីរ

សិក្សាប្រៀបធៀប អាណត្តិទីមួយនិងទីពីរ

•អាណត្តិទីមួយ

-ឆ្នាំ១៩៩៣

-ឧបត្ថម្ភដោយ UNTAC

អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិឧបត្ថម្ភជាប្រាក់ ២០០០លានដុល្លារ

-មានគណៈបក្សចំនួន២០ឈរឈ្មោះ

-គណៈបក្សហ៊ុនស៊ីប៊ុចជាប់ឆ្នោតច្រើនជាងគេ បន្ទាប់មកគណបក្សប្រជាជន និងសេរីនិយមព្រះពុទ្ធ សាសនា និងម៉ូលីណាកា

-មេដឹកនាំរដ្ឋាភិបាលគឺគណបក្សហ៊ុន ស៊ីប៊ុចជាប្រធាន បន្ទាប់មកគណបក្សហ៊ុនស៊ីមប៊ុចប្រជាជន ជាអនុប្រធាន

-មានសហនាយករដ្ឋមន្ត្រី

-សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ

-សម្តេច ហ៊ុនសែន

-តំលៃមិនទាន់មានម្ចាស់ការថវិការលទ្ធភាពនៃការបោះឆ្នោត

•លក្ខណៈដូច

-អនុវត្តន៍តាមលិទ្ធិប្រជាធិបតេយ្យ

-បោះឆ្នោតជាសកល ជាសង្ងាត់ត្រឹមត្រូវសេរី និងយុត្តិធម៌ អាណត្តិទី២ ១៩៩៨

-រៀបចំដោយរាជរដ្ឋាភិបាលតែមាន

-ការជួយឧបត្ថម្ភខ្លះ ពីអង្គការអន្តរជាតិពិសេសគឺសហគមន៍អឺរុប

-គណបក្សចំនួន ៣៩ឈរឈ្មោះ

-គណបក្សប្រជាជនមានសំលេងច្រើនបន្ទាប់មក ហ៊ុនស៊ីប៊ុច និងគណបក្សសមរង្ស៊ី

-មេដឹកនាំរដ្ឋាភិបាល គឺគណបក្សប្រជាជន

-មានតែនាយករដ្ឋមន្ត្រីតែមួយគឺ សម្តេច ហ៊ុនសែនជាប្រមុខនៃរដ្ឋាភិបាល

-តំលៃស្ថិយម្ចាស់ការទាំងខាងសន្តិសុខ

២៧៩.ក.ចូរអ្នកសិក្សារប្រៀបធៀបការចុះឈ្មោះបោះឆ្នោត និងការឈរឈ្មោះឱ្យគេបោះឆ្នោត?

ចំ.ក. សិក្សាប្រៀបធៀបការចុះឈ្មោះបោះឆ្នោត និងការឈ្មោះបោះឆ្នោត

*លក្ខណៈខុស

-ការចុះឈ្មោះបោះឆ្នោត ការឈរឈ្មោះបោះឆ្នោត

-មានសញ្ជាតិជាខ្មែរពីកំណើត

-អាយុចាប់ពី១៨ឆ្នាំឡើងទៅគិតដល់ថ្ងៃ

-មានអាយុចាប់ពី២៥ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត

-មានអាស័យដ្ឋានច្បាស់លាស់

-ស្នាក់នៅកម្ពុជាយ៉ាងតិចមួយឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត(មានអាស័យដ្ឋានច្បាស់លាស់)

-មិនស្ថិតក្នុងស្ថានភាពជាប់ពន្ធធនាគារ

-មានសិទ្ធិបោះឆ្នោត

-មិនមែនជាជនវិកលចរិក

-មានឈ្មោះក្នុងបញ្ជីគណបក្សដែលតែងតាំង ក្រោមអណាព្យាបាលសមត្ថកិច្ចណាមួយ មកក្នុងបញ្ជីឈរឈ្មោះបោះឆ្នោត

*លក្ខណៈដូច :

-ការកំនត់អាយុ -ជាពលរដ្ឋ(ជនស្ថិតនៅក្នុងច្បាប់)

-មានសញ្ជាតិជាខ្មែរ -មិនពាក់ព័ន្ធនឹងពិរុទ្ធនានា

-មានសតិគ្រប់គ្រាន់

ខ. ប្រភេទដែលគ្មានសិទ្ធិបោះឆ្នោត ឬក៏គ្មានសិទ្ធិឈរឈ្មោះបោះឆ្នោតគឺ:

-អនីតិជន(មានអាយុក្រោម១៨ឆ្នាំ) -ជនបរទេស

-ទណ្ឌិត(អ្នកទោស) -ជនវិកលចរិកឬមានសតិគ្រប់គ្រាន់

-ជនដែលស្ថិតក្នុងអាណាព្យាបាលនៃស្ថាន មានសមត្ថកិច្ច

២៨០.តើអាចដោះស្រាយទិដ្ឋភាសេដ្ឋកិច្ចប្រទេសមួយដោយនិធីណា?

ចំ.គេអាចដោះស្រាយវិបត្តិសេដ្ឋកិច្ចប្រទេសមួយដោយវិធី :

-ធ្វើការអភិវឌ្ឍន៍ធនធានមនុស្សឱ្យបានទូលំទូលាយក្នុងផ្ទៃប្រទេស

-យកចិត្តទុកដាក់បណ្តុះបណ្តាលអ្នកបច្ចេកទេស វិទ្យាសាស្ត្រ

-រដ្ឋាភិបាលត្រូវធ្វើឱ្យមានលំនឹងផ្នែកនយោបាយ

-ត្រូវរកទីផ្សារសំរាប់លក់ផលិតផលឱ្យពេលវេ

-ឆ្លោភិបាលត្រូវបំបាត់ឱ្យបានន្ទូវអំពើពុករលួយ

-រដ្ឋត្រូវមានការធានាសន្តិសុខ សុវត្ថិភាព ប្រជាជន និងវិនិយោគទុន

-រដ្ឋត្រូវមានផែនការក្នុងដំណើរការប្រចាំនីមួយ។

២៨១.ដើម្បីអនាគតរបស់ខ្លួនយើងត្រូវយកចិត្តទុកដាក់ដល់កុមារដូចម្តេច?

ចំ.ដើម្បីអនាគតរបស់ខ្លួនយើងត្រូវយកចិត្តទុកដាក់ដល់កុមារដូចជា :

-ត្រូវឱ្យកុមាររស់ដោយសន្តិភាពក្នុងស្ថានណាក៏ដោយ

- ត្រូវឱ្យគេរស់ដោយសុខស្រួលជាក្រុមគ្រួសារ

- ត្រូវឱ្យមានការអប់រំ ការអភិវឌ្ឍន៍កាយសម្បទារ បញ្ញាស្មារតី

- ត្រូវទទួលស្គាល់មតិរបស់កុមារយកទៅពិចារណា

-មិនត្រូវបំពាក់បំពានលើរាងកាយនិងចិត្តគំនិតរបស់កុមារ

- មិនត្រូវរំលោភលើផ្នូវភេទទៅលើកុមារ

- មិនត្រូវត្រូវគេងប្រវ័ញ្ចលើសេដ្ឋកិច្ចកុមារ និងពលកម្មលើកុមារ

- មិនត្រូវឱ្យកុមារធ្វើការហួសកំនត់ ឬហួសកំលាំង

- មិនត្រូវមានការជួញដូរលើកុមារជាដាច់ខាត

២៨២.ចំនេះដឹងរបស់មនុស្សមានប៉ុន្មានប្រភេទ? មានលក្ខណៈដូចម្តេច?

ចំ. +ចំនេះដឹងរបស់មនុស្សមាន ពីប្រភេទ:

-ចំនេះដឹងបែបសាមញ្ញ ឬ ចំនេះដឹងធម្មតា(ពុទ្ធសាមញ្ញ)

- ចំនេះដឹងបែបវិទ្យាសាស្ត្រ(ពុទ្ធស្បង់)

- ចំនេះដឹងបែបទស្សនវិជ្ជា ឬពុទ្ធទស្សនវិជ្ជា

+ ចំនេះដឹងនេះមានលក្ខណៈខុសគ្នាដូចតទៅ :

ពុទ្ធសាមញ្ញ	ពុទ្ធស្បង
-ចំនេះដឹងកិរិតទាប	- ចំនេះដឹងកិរិតខ្ពស់
-កើតពីតន្ត្រីអារម្មណ៍	-កើតពីការត្រិះរិះល្អិតល្អន់នៃបញ្ហាពីបញ្ហា ស្បង់ឬវិទ្យាសាស្ត្រជាការខិតខំស្វាប់ និងពន្យល់អ្វីដែលមាន

-ទទួលបានពីការស្តាប់វិទ្យុ ឮតៗគ្នា ឃើញ
ឬអានទស្សនាវដ្តី

-ឈរលើបទពិសោធន៍ជាជាង

-ឈរលើបទពិសោធន៍ជាក់ស្តែងដោយប្រើ
វិចារណញ្ញាណ

-ងាយច្រលំ ។ខ.វត្ថុធ្ងន់តែងតែលិចទឹក

-មិនងាយច្រលំ ។ខ.ទឹកពុះនៅ១០០អង្សា
តែកកនៅ ០ អង្សា ពុទ្ធទស្សនៈវិជ្ជា

- ចំនេះដឹងខ្ពស់បំផុតកើតពីការពិចារណាល្អិតល្អន់ពីការពិបញ្ហា មនុស្សមានបញ្ហាស្មុគ់ផងដែរ
- ឈរលើវិចារណញ្ញាណទាញចេញពីការអនុវត្តជីវិតពិត
- មិនងាយច្រលំ

ឧទាហរណ៍ : មានរូបមានទុក្ខ

២៨៣.តើការអប់រំបានពង្រីកបុគ្គលិកលក្ខណៈមនុស្សដូចម្តេច?

ចំ. ការអប់រំបានពង្រីកបុគ្គលិកលក្ខណៈមនុស្សឱ្យមានការអភិវឌ្ឍន៍ទាំងផ្នែករាងកាយ ទាំងខាងបញ្ញា
ទាំងខាងស្មារតី ដូចជា:

*ខាងផ្នែករាងកាយ(អប់រំកាយ) បានពង្រីកនូវលក្ខណៈមនុស្សដូចជា :

-ធ្វើឱ្យមនុស្សមានរាងកាយមាំមួន

-មានសុខភាពល្អ

-មានកំលាំងខ្លាំងក្លា

*ខាងផ្នែកបញ្ញា(អប់រំបញ្ញា) ការអប់រំបានបណ្តុះបណ្តាល និងពង្រីកបញ្ញាមនុស្សដូចជា :

-មានបញ្ញាវាងវៃឆ្លាត

-បណ្តុះបណ្តាលនូវពុទ្ធិវិទ្យាសាស្ត្រចំនើប

-ចេះត្រិះរិះពិចារណារកហេតុផលដោយប្រើអព្ភន្តរញ្ញាណ និងវិចារណញ្ញាណ

-ចេះដោះស្រាយបញ្ហាផ្សេងៗចំពោះមុខបានយ៉ាងងាយ

-ចេះផ្លែប្រឌិតនូវឧបករណ៍ សំភារផ្សេងៗប្រកបដោយបច្ចេកទេសល្អឿនល្អឿន

-កែច្នៃរាល់កិច្ចការនានាឱ្យដើរស្របនឹងកាលៈទេសៈ

*ខាងផ្នែកស្មារតីច្នៃត្រិតនិងមានសតិភ្ញាក់រឭកដឹងនូវអ្វីដែលខ្លួនបាននឹងកំពុងធ្វើ ហើយនិង ត្រូវធ្វើដូចជា :

-ធ្វើឱ្យមានវិចារណញ្ញាណ និងឧត្តមគតិ

-ឱ្យមនុស្សស្គាល់ខ្លួនឯងដោយចេះធ្វើម្ចាស់លើចិត្តរបស់ខ្លួន

-មានការទទួលខុសត្រូវខ្ពស់ ពីអំពើដែលខ្លួនធ្វើ

-មានសីលធម៌ល្អ

២៨៤.តើស្ត្រីដែលមានការអប់រំ មានចំនេះដឹងច្បាស់ មានឥរិយាបថដូចម្តេច?

ចំ. ស្ត្រីដែលបានទទួលការអប់រំមានចំនេះដឹងទូទៅច្រើនតែមានឥរិយាបថល្អចំពោះខ្លួនឯង និងសង្គមដូចជា :

*ឥរិយាបថចំពោះខ្លួនឯង

-មានសកម្មភាពអាចចិញ្ចឹមគ្រប់គ្រងគ្រួសារបានល្អ

-ចេះធ្វើម្ចាស់ការលើការងារ និងមានការទទួលខុសត្រូវ

-ចេះថែរក្សាសុខភាពរបស់ខ្លួន

-មានការសំរេចចិត្តបានច្បាស់លាស់(មានរឆ្នះ)

-មានគំនិតជឿនលឿន មានអធ្យាស្រ័យល្អ(ចិត្តទូលាយ)

-ចេះបង្កឱ្យមានបរិយាកាសរីករាយ

*ឥរិយាបថចំពោះគ្រួសារ ការរៀបចំផែនការ

-ផែនការសេដ្ឋកិច្ច :

=សន្សំសំចៃ =ចាយវាយមានការច្បាស់លាស់

=ចេះច្នៃប្រឌិតការងារមេផ្ទះ

-ផែនការគ្រួសារ :

=ចេះកំនត់ចំនួនកូនបានត្រឹមត្រូវ

=ចេះរៀបចំផែនការពន្យាកំណើត ឃល់ដឹងពីអនាម័យ វិធីបង្ការជំងឺផ្សេងៗ

-ផែនការអប់រំ

=អប់រំសុខភាពឱ្យកូនចៅ សាមីឱ្យចេះថែរក្សាសុខភាព

=អប់រំសីលធម៌ដល់គ្រួសារពិសេសបុត្រធីតាឱ្យឃល់ពីតំលៃ និងធ្វើខ្លួនឱ្យទៅជាមនុស្សមាន

=អប់រំវប្បធម៌ទូទៅ បន្តនូវប្រពៃណីល្អៗរបស់ជាតិ

*ចំពោះសង្គម

-ចេះបង្កើតស្នាដៃធ្វើឱ្យសង្គមនិងស្វាមីទទួលស្គាល់

-មានមំនាក់មំនងល្អចំពោះសង្គម

-មានមុខតំនែងក្នុងសេវាកម្មសាធារណៈ

*ចំពោះប្រទេសជាតិ

-បានជួយពន្លឿនដំណើរការមនុស្សថ្មីស្រុនទៅនឹងវិទ្យាសាស្ត្រថ្មី

-ផ្តល់នៅពលរដ្ឋល្អជូនប្រទេសជាតិ ស្ត្រីទទួលបាននូវការអប់រំមានចំនេះដឹងអាចធ្វើឱ្យគ្រួសារមាន
សុភមង្គល និងធ្វើឱ្យប្រទេសជាតីរីកចំរើន ។

២៨៥.តើសិទ្ធិពិសេសចាំង ៦របស់នារីមានអ្វីខ្លះ?

ចំ.សិទ្ធិពិសេសទាំង ៦របស់នារីមាន :

-សិទ្ធិទទួលប្រាក់បំនាច់ស្មើនឹងបុរស ក្នុងការងារដូចគ្នាត្រូវទទួលប្រាក់ខែស្មើគ្នា

-សិទ្ធិមានសកម្មភាពខាងផ្នែរភេទ ភេទណាក៏ដោយក៏ដូចគ្នា អាចធ្វើអ្វីមួយបានតាមសកម្មភាព----
សិទ្ធិមានសកម្មភាពរវាងប្តីប្រពន្ធ ភាពជាប្រពន្ធមានតំលៃស្មើប្តី

-សិទ្ធិទទួលកិច្ចការការពារកេងប្រវ័ញ្ច មិនឱ្យគេងប្រវ័ញ្ចលើស្ត្រីគ្រប់មធ្យោបាយ

-សិទ្ធិឈប់សំរាកពេលសំរាលកូន អាចឈប់មុនពេលក្រោយពេលសំរាកតាមការកំនត់របស់ច្បាប់---
សិទ្ធិរួចផុតពីទោសប្រហារជីវិត ក្នុងករណីប្រភេតមានទោសប្រហារជីវិតស្ត្រីមានផ្ទៃពោះ ។

២៨៦.ក.តើការរះបោះឆ្នោតមានន័យអ្វីខ្លះ ?សំរាប់ប្រជាពលរដ្ឋ និងមាតុភូមិ ?

ខ.តើការរះបោះឆ្នោតតាមបែបប្រជាធិបតេយ្យគោរពតាមលក្ខខ័ណ្ឌអ្វីខ្លះ ?

ចំ.ក.សំរាប់ប្រជាពលរដ្ឋ និងមាតុភូមិ ការបោះឆ្នោតមានន័យដូចតទៅ :

-ជាឱកាសអនុញ្ញាតឱ្យ ប្រជាពលរដ្ឋច្រើនប្រាស់សិទ្ធិ នយោបាយគ្រប់ច្បាប់របស់ខ្លួន ។

--ពលរដ្ឋអាចផ្តល់អំនាច ឬដកហូតអំនាចពីតំនាងរបស់ខ្លួនតាមបោះឆ្នោត ។

-ជាការផ្តល់អំនាចគ្រប់គ្រងដោយស្តីវិធី ដោយគ្មានអណាព្រើហ៊ីងរ្យារ ។

ខ.ការបោះឆ្នោតតាមប្រជាធិបតេយ្យ ត្រូវគោរពតាមគោលការណ៏:

-លក្ខការណ៏ទូទៅ :ពលរដ្ឋទាំងពីរភេទអាចចុះឈ្មោះបោះឆ្នោត (ចាប់ពីអាយុ១៨ឆ្នាំ
និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត)(អាយុ២៥ឆ្នាំ) ។

-លក្ខការណ៏ : គ្មានការបង្ខិតបង្ខំគំរៀមគំហែងមានសេរីភាព ចូលរួមក្នុងការឃោសនា និងការសំដែងរន្ទះ ។

-ដោយចំពោះ : ទៅចុះឈ្មោះ និងទៅបោះឆ្នោត ដោយផ្តាល់ខ្លួនឯង ។

-ស្មើភាព : ម្នាក់ៗបោះបានតែមួយសន្លឹក តំលៃសន្លឹកឆ្នោតស្មើគ្ន ។

-ដោយសង់ងាត់ : លក្ខការណ៍សង់ងាត់ក្នុងបន្ទប់ ។

-យុត្តិធម៌ និងស្មើភាព : មានអ្នកសង្កេតការជាតិនិងអន្តរជាតិ ពំនាងគណៈបក្សនយោបាយ
មានអាជ្ញាធរបោះឆ្នោតឯករាជ្យទទួលបាន ការផ្សព្វផ្សាយដូចគ្នាស្មើគ្នា ។

-ត្រឹមត្រូវ : ពិតប្រាកដគ្មានការខ្វែងសន្សំសន្ឋឹកឆ្នោត ឬហិបឆ្នោត ។

២៨៧.ក.ដូចម្តេចដែលហៅថា ឧត្តមភាពក្នុងទីជ្ឋាជីវៈ ?

ខ.ដើម្បីស្វែងរកឧត្តមភាពក្នុងទីជ្ឋាជីវៈ តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ?

ចំ.ក.ឧត្តមភាព គឺជាភាពប្រសើរ ថ្លៃថ្នូ ភាពឧត្តុង្គឧត្តម ភាពល្អប្រសើរខ្ពង់ខ្ពស់ ។
ឧត្តមភាពក្នុងវិជ្ជាជីវៈ គឺវិជ្ជជីវៈដល់ល្អប្រសើរ សមដៅយកវិជ្ជាជីវៈ មានជំនាញច្បាស់លាស់
មានស្នាដៃល្អទទួលបានជោគជ័យ ។

ខ.ដើម្បីស្វែងរកឧត្តមភាពក្នុងវិជ្ជាជីវៈ ខ្ញុំត្រូវ
-មានមា្ចស់ការក្នុងការធ្វើការងារវិជ្ជាជីវៈ
-មានស្មារតីទទួលខុសត្រូវ
-ចេះស្វែងយល់ស្រាវជ្រាវបទពីសោធន៍ល្អៗពីមនុស្សចាស់ ពីបណ្ឌិតជាតិ និងអន្តរជាតិ
-ខិតខំច្នៃប្រឌិត បង្កើតស្នាដៃឱ្យមានគុណភាពខ្ពស់
-ស្វែងយល់ពីចំនុចខាំង ចំនុចខ្សោយ ដើម្បីកែប្រែ
-ស្រាវជ្រាវ និងស្វែងយល់ពីតំរូវការរបស់សង្គម ហើយខិតខំបំពេញតំរូវការនោះ ។

២៨៨.តើបណ្តឹងចែករចេញជាប៉ុន្មានយ៉ាង ?អ្វីខ្លះ ?ចូរបញ្ជាក់?

ចំ.បណ្តឹងចែករចេញជា៤គឺ :
-បណ្តឹងអាជ្ញា (បទល្មើសព្រហ្មទណ្ឌ) គឺបណ្តឹងដែលកើតពីការធ្វើឱ្យខូចសណ្តាប់ធ្នាប់ប្រៀបរាប់រយសាធារណៈ។
-បណ្តឹងរដ្ឋបវេណី (បទល្មើសរដ្ឋបវេណី) គឺបណ្តឹងដែលកើតពីការធ្វើអោយខូចខាតសម្បត្តិអ្នកដទៃ
ហើយត្រូវបញ្ឈប់ងងឹងចិត្ត ពៅអ្នករងគ្រោះ ។
-បណ្តឹងឥវ៉ា (បណ្តឹងឧទ្ធរណ៍ ជាបណ្តឹងដែលចុងចោទ ឬដើមចោទមិនយល់ព្រម
ចំពោះសាលក្រមសាលាក្រមងខេត្ត-ក្រុង ហើយបណ្តឹងមកសាលាឧទ្ធរណ៍ឱ្យជំរះហក្តីម្តងទៀត ។
-បណ្តឹងបរិហា :ជាបណ្តឹងដែលធ្វើឡើងដោយបុគ្គលម្នាក់ ឬច្រើនអ្នកដែលមិនពេញចិត្តចំពោះបុគ្គល
ស្តាប់រដ្ឋ ឬរដ្ឋាភិបាលដែលប្រព្រឹត្តខុសច្បាប់ ធ្វើអោយប៉ះពាល់ដល់ដល់ប្រយោជន៍ ឬសម្បត្តិរដ្ឋ ដូចជាគេងបន្ទំ
ស៊ីសំណូកសូកប៉ាន ជាដើម ។

២៨៩.តើសេចក្តីសុខរបស់មនុស្សតាមទស្សនៈរបស់ព្រះពុទ្ធជាម្ចាស់មានប៉ុន្មានប្រការ? ចូរពន្យល់ឱ្យបានច្បាស់លាស់ ។

ចំ.សេចក្តីសុខរបស់មនុស្សតាមទស្សនៈព្រះពុទជាម្ចាស់មាន៥ប្រការ ។ សេចក្តីសុខទាំង៥ប្រការនោះមាន :

-អត្ថិសុខ : ជាសេចក្តីសុខព្រោះមានទ្រព្យសម្បត្តិ គ្រប់គ្រាន់ តាមតម្រូវការ ។ទ្រព្យសម្បត្តិទាំងនោះមាន៤ប្រការ :

-ច័ន្ទីរអាហារគ្រប់បែបយ៉ាង

-សំលៀកបំពាក់ គ្រឿងបិទបាំងរាងកាយ គ្រឿងអលង្ការសមគួរ ។

-គេហដ្ឋានជំរកសមរម្យជារបស់ខ្លួន ព្រមទាំងសំភារៈប្រើប្រាស់ក្នុងផ្ទះ

-ថ្នាំជង្ងឺរបស់ព្យាបាល មានគ្រូពេទ្យជួយថែទាំជំងឺ

•ភោគសុខ :ជាសេចក្តីសុខដែលកើតពីការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយត្រឹមត្រូវរឹករាយ ជាសេចក្តីសុខព្រោះបានប្រើសម្បត្តិ ខ្លួនបានរកមកដោយសុចរិតត្រឹមត្រូវ ។

អនពសុខ :សេចក្តីសុខ

ព្រោះគ្មានបំណុលសេចក្តីសុខកើតពីការបានប្រព្រឹត្តិតាមគន្លងធម៌ជាសេចក្តីសុខព្រោះមានការងារ សុចរិតជាបង្គោលជាប់លាប់ធនារក ទ្រព្យប្រាក់កាស ។

-សន្តិសុខ:ជាសេចក្តីស្ងប់ព្រោះមានចិត្តស្ងប់ មិនរឹកវរច្របូកច្របល់ ច្របូកច្របល់ច្រនែនឈ្នានីស ។

-សរុបសេចក្តីមកសេចក្តីសុខ ទាំង ៥ប្រការ ជាតំរូវការ និងគោលបំនង របស់មនុស្សជាតិ មនិជាអ្នកណាជាអ្នកណាឡើយ ។

២៩០.តើការបោះឆ្នោតបែបប្រជាធិបតេយ្យមានអត្ថន័យយ៉ាងណាខ្លះ?ចូរពន្យលឱ្យបានច្បាស់លាស់ ។

ចំ. ការបោះឆ្នោតបែបប្រជាធិបតេយ្យមានន័យដូចត ទៅ:

-ការបោះ ឆ្នោតបែបប្រជាធិបតេយ្យជាការបោះឆ្នោត:

-ប្រណាំង -ដោយសេរី

-ខ្សែងមាត់ពេល -ជាសំងាត់

-ស្មើភាព -ចូលរួមគ្នា

-ជាចំណាត់តាមរយការបោះឆ្នោត

-រដ្ឋាភិបាលត្រូវជ្រើសរើសពាយប្រជាជនតាមរដ្ឋសភា

-រដ្ឋសភាត្រូវជ្រើសរើសដោយប្រជាជន

-នៅពេលយុទ្ធនាការឃោសនាបោះឆ្នោតគណបក្ស និងបេក្ខជនរបស់គណបក្សត្រូវមាន:

•សេរីភាពក្នុងការនិយាយស្តី • ជួបប្រជុំ

•ធ្វើដំណើរចាំបាច់ដើម្បីផសព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន

•ការបោះឆ្នោតបែបប្រជាជនមិនជ្រើសរើស:

-ជនផ្តាច់ការ -ប្រធានាធិបតេយ្យ៏ អ្នកដឹកនាំ១ជីវិត

-មន្ត្រីរឹតនាងដែលប្រជាជនជ្រើរើសត្រូវតែទទួលខុសត្រូវ ចំពោះមុខប្រជាជន

ហើយការបោះឆ្នោតត្រូវគិតពីប្រយោជយ៏ប្រជាជនជាធំ ។

២៩១.តើសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នអនុវត្តតាមប្រពន្ធអ្វី? ពន្យល់ក្រួសៗ ពីស្ថានភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា

ចំ.ក...ជាទូទៅវិសយសេដ្ឋកិច្ចព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលបានប្រើប្រពន្ធសេដ្ឋកិច្ចចំរុះ ។

ខ..ភាគច្រើននៃមធ្យោបាយផលិតកម្មជាកម្មសិទ្ធ ឯកជន ប៉ុន្តែ រដ្ឋភិបាលដើរតួនាទីសំខាន់ក្នុងដឹងនាំ

និងធ្វើឱ្យសេដ្ឋកិច្ចលំនឹង។ សេដ្ឋកិច្ចចំរុះផ្តល់នូវវិធីដ៏មានប្រសិទ្ធភាព ក្នុងការផ្តល់អាជីវកម្មដល់អតិថិ ជន។

ប្រជាជនកម្ពុជាបានធ្វើសមាហរណកម្មយ៉ាងរហ័សក្នុងប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ និងក្នុងតំបន់

ក្នុងគោលបំនងដើម្បីទទួលយកផលប្រយោជន៍ចំពោះប្រជាជមខ្លួន ។នៅខណៈពេលដែលរដ្ឋាភិបាល

ត្រូវជួយការពារបុគ្គលិកកម្មករនិងអតិថិជន ពីការបាក់បែករំលោភបំពានពីសំនាក់ម្ចាស់អាជីវកម្ម ។

២៩២.តើយុវជន ដែលថាសសរទ្រួចប្រទេសជាតិ ត្រូវចូលរួមចំណែយអភិឌ្ឍន៍ សហគមន៍ សង្គមដូចម្តេច?

ចំ.យុវជនដែលមានសក្តានុភាពមិនអាចវាស់ និង ប៉ាន់ប្រមាណហើយត្រូវចូលរួមអភិវឌ្ឍន៍ សង្គមដូចខាងក្រោម:

-រៀបចំខ្លួនឱ្តតខំសែវងរកចំនេះដឹង ជំនាញវិជ្ជាជីវៈ

-មានអកប្បកិរិយា សមរម្យ សីលធម៌រស់នៅស្អាតស្អំ ធ្វើអ្វីៗ ស្របតាមច្បាប់សង្គម ទំនៀមទំលាប់ ប្រពៃណីខ្មែរ។

-ចូលរួមសហការគ្នា ក្នុងការធ្វើអ្វីមួយឱ្យ អស់ពីកំលាំងកាយចិត្ត បញ្ញាជាថាមពល និងមានសកម្ម ជានិច្ច។

-ជួយថែរក្សាអ្វីៗគ្រប់យ៉ាង ដើម្បីឱ្យមានធនធានភាពសំរាប់មនុស្សជំនាន់ក្រោយ ។

-មានគំនិតផ្តួចផ្តើម ក្នុងការជួយអភិវឌ្ឍន៍ សហគមមិនចាំបាច់តែមនុស្សចាស់ទេ ។

-មិនប្រើប្រាស់ថ្នាំញៀន ជួយទប់ស្កាត់ ប្រជាជនមិនឱ្យប្រព្រឹត្តអំពើអ្វីដែលសង្គមស្អប់ខ្ពើម ។

២៩៣.ត្រប់សាសនាចាំបាច់ទាស់បានឱ្យសាសនិកជនយកចិត្តទុកដាក់ពីបញ្ហាជំងឺអេដស៍ បរិស្ថាន សង្គ្រាម ។តើគេអាចដោះស្រាយបញ្ហាចាំបាច់នេះដោយវិធីណាខ្លះ?

ចំ.ត្រប់សាសនាទាំងអស់ បានឱ្យសាសនិកជនយកចិត្តទុកដាក់ពីបញ្ហាជំងឺអេដស៍ បរិស្ថាន សង្គ្រាម ។

គោដោះស្រាយបញ្ហាទាំងនេះដូចតទៅ:

ក..ជំងឺអេដស៍:ត្រូវផ្សព្វផ្សាយ ពីផលវិបាកនៃជំងឺអេដស៍ និងវិធីការពារដូចតទៅ:

-ប្រើវិធីការពារប្រសើរជាងព្យាបាល

-ពិនិត្យរកមេរោគមុនបញ្ចូលឈាម -មានដៃគូរួមភេទច្រើន

--មិនសេពគ្រឿងញៀនស្រវឹង -មិនចាក់ថ្នាំប្រើស៊ីរ៉ាំងរួមគ្នា

-ជួយថែទាំលើកទឹកចិត្តអ្នកកើតអេដស៍

ខ...អំពីបរិស្ថាន : ផ្សព្វផ្សាយជំពីការថែរក្សាសម្បត្តិធម្មជាតិដូចជា:

-ថែរក្សាព្រៃឈើ ឈប់កាប់បំផ្លាញ ចូលរួមដាំដើមឈើ

-ថែរក្សារបរិយាកាស បន្ថយផ្សែងពេលដែលបង្ហុយចូលបរិយាកាស បន្ថយកំដៅដែលមនុស្សបង្កើត ។

-ថែរក្សាទឹកមិនចោលសំរាមកាកសំនល់ចូលក្នុងទឹក

-ថែរក្សាជីវកសត្វ ធម្មជាតិមិនខេសាទត្រីក្នុងរដូវត្រីពង

គ....អំពីបញ្ហាសង្គ្រាម :

-បញ្ចប់សង្គ្រាមដោយចរចារ

-ដោះស្រាយសង្គ្រាមដោយធម្មយាត្រា

-ផ្តល់សម្បទានឱ្យគ្នាទៅវិញទៅមក

-ឈប់ផលិតប្រល័យលោក

២៩៤. ដើម្បីក្លាយជាមនុស្សមែនទែន តើមនុស្សម្នាក់ត្រូវមានលក្ខណសម្បត្តិអ្វីខ្លះ?

ចំ.ដើម្បីក្លាយជាមនុស្សមែនទែនម្នាក់ៗត្រូវមានលក្ខណ :

-ធ្វើជាគំរូល្អដល់អ្នកជុំវិញ -ជួយយកអសារអ្នកជុំវិញ

-មានចំនួលខុសត្រូវចំពោះទង្វើរបស់ខ្លួន

-គិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយមុនធ្វើអ្វី១

-លើកគុណសម្បត្តិអ្នកជុំវិញដែលបានជួយខ្លួន

-ស្រលាញ់អ្នកជុំវិញដោយចិត្តស្មោះ -ជួយកែកំហុសអ្នកជុំវិញ

-ចេះមើលឱ្យឃើញកំហុសរបស់ខ្លួនឯង

-ចេះកំណត់គោលដៅ របស់ខ្លួនបានច្បាស់លាស់

-បង្កើនចំណេះដឹង បច្ចេកទេសជាប្រចាំ

២៩៥.តើក្រមសីលធម៌សំរាប់សហស្សវត្សថ្មី ចំពោះគ្រួសារមានអ្វីខ្លះ?

ចំ...ក្រមសីលធម៌សំរាប់សហស្សវត្សថ្មីចំពោះគ្រួសារមានដូចជា:

-ជួយធ្វើការងឺពុកម្តាយ និងគោរពតាមជំបូន្មាន ពាំងខ្លួនជាកូនល្អ

-ចេះថែរក្សាការពារ និងស្រលាញ់បងប្អូន

-ផ្តល់រាល់តំរូវការចាំបាច់សំរាប់ជីវិតគ្រួសារ

-ពិគ្រោះពីសុខទុក្ខ ផលប្រយោជន៍គ្រួសារ

-មានព្រហ្មវិហារធម៌ ចំពោះគ្រួសារ

-ជាពីសេសត្រូវមានភាពស្មោះត្រង់ចំពោះគ្រួសារ

២៩៦.ក.តើគោលការណ៍ថាមូលដ្ឋានស្តីអំពី ឯករាជ្យភាពនៃក្រមចៅក្រមដូចម្តេចខ្លះ?

ខ..តើតុលាការមានសារសំខាន់ដូចម្តេច? ចំពោះឥឥតាពរស់នៅរបស់ប្រជាជន?

ចំ. គោលការណ៍មូលដ្ឋានអំពីឯករាជ្យភាពនៃក្រមចៅក្រម

ក..ចៅក្រមត្រូវកាត់ក្តីតាមគតិយុត្តិធម៌ ជៀសវាងអគតិទាំង ៤ ឆន:គតិ ទោសោគតិ មោហោគតិ និង ភយាគតិ ។

-កាត់ក្តីដោយគោរពទៅតាមច្បាប់ របស់សង្គម

-កាត់ក្តីដោយផ្អែកលើហេតុផលការណ៍ ដែលមានចំពោះមុខ

ខ.តុលាការមានសារសំខាន់ ប្រជាជនប្រទេសជាតិដូចតទៅ:

- រក្សាសណ្តាប់ធ្នាប់ក្នុងប្រទេសជាតិ
- ការពារសន្តិសុខដល់ប្រជាពលរដ្ឋគ្រប់រូប
- ការពារសិទ្ធសេរីភាពរបស់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋមានលំនឹងក្នុងចិត្ត ព្រោះមានតុលាការចាំជួយការពារ
- ជួយរកយុត្តិធម៌ ធ្វើឱ្យប្រជាពលរដ្ឋគ្រប់ថ្នាក់ត្រូវតែគោរពច្បាប់មិនហ៊ានបំពាន ព្រោះគ្មានតុលាការចាំនិច្ឆយទោស ។
- ជីវ:ភាពរស់នៅរបស់ប្រជាពលរដ្ឋបានល្អប្រសើរ ព្រោះជីវភាពរស់នៅត្រូវបានធានាដោយច្បាប់ ។

- ឯករាជភាពនៃតុលាការ ធ្វើឱ្យអង្គការជាតិ អន្តរជាតិ អ្នកវិនិយោគជា និងបរទេស មានទំនុកចិត្តលើប្រទេសជាតិទាំងមូល ព្រោះមានច្បាប់មានប្រពន្ធតុលាការល្អ ។

២៩៧.នៅក្នុងប្រទេសតតិយរលោកតែងតែថ្លឹងប្រៀបធៀបនូវអតុល្យភាព ដែលធ្វើឱ្យដំណើរការអភិវឌ្ឍន៍ប្រទេសមានការយឺតយ៉ាវ ។ តើអតុល្យភាពសមខាន់ៗមានអ្វីខ្លះ?

ចំ.នៅប្រទេសតតិយលោកតែងតែជួបប្រទះនូវអតុល្យភាព ដែលធ្វើឱ្យដំណើរការអភិវឌ្ឍន៍ប្រទេសមានការយឺតយ៉ាវ ។

អតុល្យភាពសំខាន់ៗរួមមានដូចជា :

-សំនួមពរនិងសេចក្តីត្រូវការ

-ចំណូលនិងជំនាយ

-ការនាំចេញ និងការនាំចូល

-រូបិយវត្ថុនិងម៉ូនិញ

-ប្រាក់ប្បៀវត្ស និងជីវភាពរស់នៅរបស់មន្ត្រីរាជការ

-កំលាមងពលកម្មនិងការងារធ្វើ

-សំណូមពរ អភិវឌ្ឍន៍ ប្រទេសជាតិនិងធនធានមនុស្ស

-សំណូមពរ អភីវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ ។

២៩៨.តើនិមិត្តសញ្ញានៃក្រសួងអប់រំយុវជន និងកីឡាមានរូបភាពអ្វីខ្លះ ? ហើយជំនាងឱ្យអ្វី?

ចំ.និមិត្តសញ្ញានៃក្រសួងអប់រំយុវជននិងកីឡាមានរូបភាព ហើយជំនាងឱ្យដូចតទៅ :

-កំរងផ្កាផ្ទីទេស ពណ៌មានព័ទ្ធជុំវិញ

-ជំនាងវប្បធម៌ខ្មែរ

-តំនាងឱ្យស្រទាប់យុវជន ដែលកំពុងទទួលបានជលជាផ្កាជាផ្លែ

-រង្វង់មូលទ្រង់ភ្លើងតប់ពណ៌មាស

-និមិត្តរូបវិស័យកីឡា

-មានយុវជនជាអ្នកបន្តវេន

-កាំរស្មីពណ៌មាសចែងចាំគ្រប់ទិសទី

-ពន្លឺនៃវិជ្ជា

-ការអប់រំសតិបញ្ញោស្មារតី ប្រជាជនខ្មែរទូទាំប្រទេស

-កំនាត់ខ្សែបូពណ៌ មានចារឹកក្រសួងអប់រំយុវជន និងកីឡា

ជានិមិត្តរូបនៃវិស័យអប់រំសិក្សាដែលមានទំនាក់ទំនងនិងអន្តរជាតិ

២៩៩.តើកីឡាបានផ្តល់នូវសម្បទានអ្វីខ្លះ ? ដែលថាអត្ថប្រយោជន៍ដល់អ្នកដែលនិយមវា ?

ចំ.កីឡាបានផ្តល់នូវសម្បទាន ដែលជាអត្ថប្រយោជន៍ដល់អ្នកដែលនិយមវា ដូចជា :

-កាយសម្បទា : មានកំលាំងកាយទាំងមូល សុខភាពល្អ រហ័សរហាយន

-សិល្បសម្បទា : មានកាយមាមមួន កំពស់សមាមាត

-វិជ្ជាជីវៈ សម្បទានជាអាជីពមួយ សំរាប់របបចិញ្ចឹមជីវិត

-បញ្ញាសម្បទា :ឈ្លាតវៃចេះប្រើល្បិច ដើម្បីយកជីជំនះ

-ភោគសម្បទា : អាចរកប្រាក់ចំណូល ឬរអ្នាំពេលបានជោគជ័យ

ចំនេះដឹងសម្បទា :មានចំនេះដឹង និងសមត្ថភាពក្នុងការការពារខ្លួន ក្នុងពេលមានអាសន្ន ។

៣០០.តើអដ្ឋង្គិកមគ្គ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់មានអ្វីខ្លះ?ចូរពន្យល់?

ចំ.អដ្ឋង្គិកមគ្គ :របស់ព្រះសម្មាសម្ពុទ្ធជាមាគ៌ាប្រកបដោយអង្គប្រាំបី ដែលមានដូចតទៅ :

-សម្មាទិដ្ឋិ: ការយល់ឃើញត្រូវសម្មាសង្ប ការត្រិះរិះក្នុងផ្លូវត្រូវ ។

-សម្មាកម្មន្ត: ការត្រឹមត្រូវ

-សម្មាវិចារ

-សម្មាអាជីវ :ការចិញ្ចឹមជីវិតត្រឹមត្រូវ

-សម្មាវាយាម :ការព្យាយាមត្រឹមត្រូវ

-សមមាសតិ :ការភ្ជាក់រលឹកត្រឹមត្រូវ

-សម្មាសមាធិ : ការតាំងចិត្តត្រឹមត្រូវ ។

៣០១.តើការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា អាណត្តិទី១ ទី២ ទី៣ មានការបរិច្ចេតនៅថ្ងៃណា ? ខែណា ? ឆ្នាំណា ?

ចំ.ការបោះឆ្នោតនៅកម្ពុជាទាំងបី អាណត្តិ មានការបរិច្ចេតដូចតទៅ :

-អាណត្តិទី១ :២៣ ឧសភា ២៨ ឧសភា ១៩៩៣

-អាណត្តិទី២ ២៦ កក្កដា ១៩៩៨

-អាណត្តិទីបី ២៧ កក្កដា ២០០៣ ។

៣០២.តើមនុស្សដែលឧបត្ថម្ភចង្ហាន់ស្ថានភាពបែបណា ទើបអាចកំណត់ថា ជាជនភៀសខ្លួន ?

ចំ. និងអាចកំណត់ថា ជាជនភៀសខ្លួនគឺជាមនុស្ស ដែលមានការភ័យខ្លាច ដោយសារតែហេតុផលខាងបូជសាសន៍ ។ ហេតុផលខាងសាសនា ហេតុផលខាងសញ្ជាតិ ឬហេតុផលខាងនយោបាយ ។

៣០៣.ក្នុងអដ្ឋង្គិមគ្គរបស់ព្រះមហាពុទ្ធជាម្ចាស់ត្រង់ សម្មាអាជីវ លោកបានអប់រំ ឱ្យបុគ្គលចាំឧបាយប្រកបរបបចិញ្ចឹមជីវិត ដោយសុចរិតត្រឹមត្រូវ ពិសេសហាមលក់ ឬជួញដូរចំនិញអ្វីខ្លះ ? តើថាចំនិញអ្វីខ្លះ ?

ចំ.ក្នុងអដ្ឋង្គិមគ្គរបស់ព្រះមហាពុទ្ធជាម្ចាស់ត្រង់ សម្មាអាជីវ លោកបានអប់រំ ឱ្យបុគ្គលទាំងឡាយប្រកបរបបចិញ្ចឹមជីវិត ដោយសុចរិតត្រឹមត្រូវ ពិសេសហាមលក់ ឬជួញដូរចំនិញ៥ប្រភេទ គឺ :

-ហាមលក់ឬជួញដូរចំនិញប្រហារជីវិត

-ហាមលក់ឬជួញដូរមនុស្ស (ជួញដូរផ្លូវភេទ)

-ហាមលក់ឬជួញដូរសត្វមានជីវិត

ហាមលក់គ្រឿងពុល

-ហាមលក់គ្រឿងញៀន

ពោល គឺព្រះពុទ្ធជាម្ចាស់ ទូន្មានឱ្យយើងចិញ្ចឹមជីវិតដោយត្រឹមត្រូវ ។វាចាកការកេងប្រវ័ញ្ច បោកប្រាស់អ្នកដទៃ ធ្វើឱ្យអ្នកដទៃមិនទទួលទុក្ខទោសអាប់អោនដោយសារខ្លួន ។

៣០៤.តើបុគ្គលម្នាក់ៗត្រូវមានសិលធម៌ ចំពោះខ្លួនឯងដូចម្តេច ?

ចំ.បុគ្គលម្នាក់ៗត្រូវមានសិលធម៌ ចំពោះ ខ្លួនឯង ដូចតទៅ :

-គោរពខ្លួនឯងមានជំនឿរលើសមត្ថភាពរបស់ខ្លួន

-មិនប្រមាថមើលងាយ បន្ទាប់បន្ថោកខ្លួនឯង មានគំនិតទុទិដ្ឋិនិយម លើខ្លួនឯង ហួសពេលវេលា និងខិតខំសិក្សាបង្កើនសមត្ថភាព ដើម្បីកសាងអនាគតរបស់ខ្លួនឱ្យថ្កុំថ្កើងរុងរឿង. ។

-មានចំនួលខុត្រូវរាល់ទង្វើរបស់ខ្លួន ។

៣០៥.តើជនប្រភេទណាខ្លះ ដែលគ្មានសិទ្ធិជារបក្ខជនដោះឆ្នោត ឬត្រឹសរើសជាតំណាង រាស្ត្រ,

ចំ.ជនដែលគ្មានសិទ្ធិឈរឈ្មោះ ជាបេក្ខជនជ្រើសរើសជាតំណាងរាស្ត្រគឺ

-ជនដែលគ្មានអាយុ២៥ ឆ្នាំ មិនអាចឈរឈ្មោះបោះឆ្នោត

-ជនដែលគ្មានសញ្ជាតិខ្មែរពីកំណើត

-ជនដែលស្នាក់នៅជាអចិន្ត្រៃ (ក្នុងប្រទេសមិនគ្រប់១ ឆ្នាំគិតដល់ថ្ងៃបោះ ឆ្នោត)

-ជនដែលមិនមានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះ ឆ្នោត ។

-ជនដែលាក្នានប័ណ្ណបោះឆ្នោត —មន្ត្រីតុលាការ ក្នុងមុនតំណែង

-មន្ត្រីរាជការស្ថាស៊ីវិល ក្នុង មុខតំនែង

-កងកំលាំងនគរបាលក្នុង មុខ តំណែង

-បុព្វជិតសាសនា (អ្នកបួស) -ជនវិកលចរិត

-ជនដែលត្រូវតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីរ បទឧក្រិដ្ឋ បទមជ្ឈឹម ហើយដែលមិនទាន់ មានឥតិ សម្បទាឡើងវិញ ។

-ជនដែលត្រូវបានផ្តន្ទាទោស ដកសិទ្ធិបោះឆ្នោត ។

-ជនដែលត្រូវបានដកហូត សិទ្ធិជាបណ្តោះអាសន្នពីសិទ្ធិ បោះឆ្នោត

-ជនដែលត្រូវបានលុបឈ្មោះពី បញ្ជីបោះឆ្នោត ដោយគណកម្មាធិការ ជាតិរៀបចំការបោះឆ្នោត ។

-សមាជិកនៃគណកម្មាធិការជាតិ និង គណកម្មាធិការរៀបចំការបោះឆ្នោតជ្រើសរើសតំណាង រាស្ត្រ ។

-សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅ ក្រម

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៣០៦.ចូរអកអាងខុសគ្នារវាងការចុះឈ្មោះឆ្នោត និងការចុះ ឈ្មោះឈរជាបេក្ខជន តំណាងរាស្ត្រឱ្យគេបោះឆ្នោត?

ចំ.ភាពខុសគ្នារវាងការចុះឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះឈរ ជាបេក្ខជនតំនាងរាស្ត្រឱ្យគេបោះឆ្នោត ។

•ការចុះឈ្មោះជាអ្នកបោះឆ្នោត

-មានសញ្ជាតិខ្មែរ

-មានសិទ្ធិបោះឆ្នោត

-មានអាយុចាប់ពី១៨ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត

-មានអាស័យដ្ឋានច្បាស់លាស់ក្នុងប្រទេស ។

-មិនមែនជាជនវិកលចរិត

-មិនមែនជាជនជាប់ទោស

-ទៅចុះឈ្មោះបោះឆ្នោតដោយខ្លួនឯង

= ការឈរឈ្មោះឱ្យគេបោះឆ្នោត

-មានសញ្ជាតិខ្មែរពីកំណើត -មានប័ណ្ណបោះឆ្នោត

-អាយុ ២៥ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត

-ស្នាក់នៅជាអចិន្ត្រៃក្នុងប្រទេសកម្ពុជាយ៉ាងតិច ១ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត

-មិនមែនជាជនជាប់ពន្ធធនាគារ

-មានការតែងតាំងពីគណបក្សនយោបាយដែលចុះឈ្មោះបោះឆ្នោត ។

៣០៧.ដើម្បីអាចអភិវឌ្ឍន៍ខ្លួនឯងបាន ជាទូទៅមនុស្សម្នាក់ត្រូវមានសមត្ថភាពថា មូលដ្ឋាន។ តើសមត្ថភាពដ៏ខាងនោះអាចកើតមានតាមរយៈអ្វីខ្លះ? ចូរពន្យល់?

ចំ. ដើម្បីអាចអភិវឌ្ឍន៍ខ្លួនឯងបាន ជាទូទៅមនុស្សម្នាក់ត្រូវមានសមត្ថភាពជា មូលដ្ឋាន ។

-=សមត្ថភាពគឺជាភាពដែលអាចបំពេញកិច្ចការ១ ឱ្យសំរេចបានដោយប្រើមធ្យោបាយសព្វបែបយ៉ាង ទាំងផ្នែកកាយ វាចា ចិត្ត ។

-=សមត្ថភាពគឺ ជាការដែលគេអាចបណ្តុះបាន ប្រសិនបើគេហ្វឹកហាត់ អប់រំឱ្យបានត្រឹមត្រូវ ។

ជាទូទៅសមត្ថភាពអាចកើតមានដោយសារៈ

-អំនាចធម្មជាតិពីកំណើត -ឧបនិស្ស័យពីកំណើត

-ការហ្វឹកហាត់ ការអប់រំ

-ក្នុងបរិយាកាសដែលអំណោយផល

-តំណពូជពីម៉ែឪ ជីដូនជីតា ញាតិសណ្តាន

-ពិសោធន៍ក្នុងកិច្ចការគ្រប់បែបយ៉ាង

-កំលាំងចិត្តដែលព្យាយាមពុះពារឱ្យខាងតែបាន

-ការរៀនសូត្រត្រឹមរិះ សូរ និងការចងចាំ ។

៣០៨.តើអនក្ខរភាពផ្តល់នូវផលវិបាកអាក្រក់អ្វីខ្លះដល់បុគ្គល និង សង្គមជាតិ?

ចំ.អនក្ខរភាព :ភាពមិនចេះអក្សរ អនក្ខរភាពតែងនាំមកនូវផលអាក្រក់ដល់សាមីខ្លួនផ្ទាល់ ព្រមទាំងសង្គមជាតិដូចជាៈ

ក-វិបាកអាក្រក់ចំពោះបុគ្គលផ្ទាល់

-បាត់ម្ចាស់ការក្នុងការរស់នៅ

-ការងារទទួលបានកំរៃតិច

-ល្ងង់ខ្លៅ អាប់ឈឺអាប់ចាញ់បញ្ឆោតគេ